អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

**អង្គភាពគាំពារជនរងគ្រោះ**
**Victims Support Section**
**Section d'appui aux victimes**

ភ្នំពេញ ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១២

# សេចក្តីប្រកាសព័ត៌មាន

## អង្គភាពគាំពារជនរងគ្រោះនឹងរៀបចំវេទិកាថ្នាក់តំបន់លើកទី១ ឆ្នាំ២០១២ នៅក្រុងច្បារមន ខេត្តកំពង់ស្ពឺ សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿង ០០២

អង្គភាពគាំពារជនរងគ្រោះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) នឹងរៀបចំវេទិកាថ្នាក់តំបន់លើកទី១ ក្នុងឆ្នាំ២០១២នេះនៅខេត្តកំពង់ស្ពឺ សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន១៥០ នាក់ នៃសំណុំរឿង ០០២។ វេទិកាថ្នាក់តំបន់នេះនឹងធ្វើនៅបន្ទប់ប្រជុំ ទាសេងហេង ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ***នាថ្ងៃសុក្រ ទី ១៦ ខែមីនា ឆ្នាំ២០១២ វេលាម៉ោង១:០០រសៀល ដល់ ម៉ោង៤:៣០ រសៀល***។ *(អត្តសញ្ញាណរបស់ដើមបណ្តឹងរដ្ឋប្បវេណីនឹងត្រូវបានរក្សាជាសម្ងាត់)* ។

វេទិកាថ្នាក់តំបន់នេះមានគោលបំណង (១)ផ្តល់ព័ត៌មានថ្មីៗអំពីការវិវឌ្ឍន៍របស់ អ.វ.ត.ក ទាក់ទងនឹងសំណុំរឿង ០០២ ដល់ដើមបណ្តឹងរដ្ឋប្បវេណី (២) ដើម្បីឲ្យដើមបណ្តឹងរដ្ឋប្បវេណីទទួលបានការពន្យល់ពីមេធាវីរបស់ខ្លួននូវដំណើការនៃការបំបែកនីតិវិធីសំណុំរឿង០០២ដែលកំពុងជម្រះក្តីជាផ្នែកៗដាច់ពីគ្នា និង(៣)ដើម្បីឲ្យដើមបណ្តឹងរដ្ឋប្បវេណីទាំងនោះប្រើប្រាស់សិទ្ធិរបស់ខ្លួន។

ដើមបណ្តឹងរដ្ឋប្បវេណីទាំង១៥០នាក់ក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណីទាំង ៣,៨៦៤ នាក់ ធ្វើដំណើរមកពីខេត្តកណ្តាល កំពត ព្រៃវែង និង កំពង់ស្ពឺ មិនដែលធ្លាប់បានចូលរួមស្តាប់សវនាការនៃសំណុំរឿង០០២ក្នុងត្រីមាសទី១ ឆ្នាំ២០១២នេះទេ។ វេទិកាថ្នាក់តំបន់នេះនឹងផ្តល់ឱកាសពិសេសសម្រាប់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងដើមបណ្តឹងរដ្ឋប្បវេណីទាំង ១៥០ បានជួបគ្នាដើម្បីពិភាក្សាពន្យល់អំពីការវិវិឌ្ឍន៍ថ្មីៗនៃ សំណុំរឿង០០២ និង ស្វែងយល់អំពីដំណាក់កាលដែលដើមបណ្តឹងរដ្ឋប្បវេណីទទួលរងគ្រោះដោយឧក្រិដ្ឋកម្មផ្សេងៗគ្នាត្រូវចូលរួមនៅក្នុងដំណើរការកាត់សេចក្តីជាផ្នែកៗដាច់ពីគ្នានេះ។

អង្គភាពគាំពារជនរងគ្រោះមានផែនការរៀបចំវេទិកាថ្នាក់តំបន់ចំនួន ៨ លើកក្នុងឆ្នាំ២០១២-២០១៣ ស្ថិតក្នុងគម្រោង "អត្ថន័យនៃការចូលរួមរបស់ជនរងគ្រោះក្នុងដំណើការនីតិវិធី អ.វ.ត.ក"។ កាលពីឆ្នាំ២០០៩-២០១១ អង្គភាពគាំពារជនរងគ្រោះបានរៀបចំវេទិកាថ្នាក់តំបន់ចំនួន១៤លើករួចមកហើយ ស្ថិតក្នុងក្របខណ្ឌគម្រោង "ការធ្វើឲ្យប្រសើរឡើងដល់ការចូលរួមរបស់ជនរងគ្រោះក្នុងដំណើការនីតិវិធី អ.វ.ត.ក"

---

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖
អ៊ឹម សុភា, ប្រធានកម្មវិធីផ្សព្វផ្សាយនៃអង្គភាពគាំពារជនរងគ្រោះ
ទូរស័ព្ទចល័ត: ០៧៧ ៧៧៧ ៣៦៧, អ៊ីម៉ែល: im.sophea@eccc.gov.kh